Australian Government
Services Australia

KHMER

# បញ្ជីត្រួតពិនិត្យគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ

ប្រសិនបើអ្នកព្រួយបារម្ភអំពីសុវត្ថិភាពរបស់អ្នក ឬសុវត្ថិភាពគ្រួសាររបស់អ្នក យើងអាចជួយបាន។ តទៅនេះគឺជារឿងមួយចំនួនដែលត្រូវចងចាំ ប្រសិនបើអ្នកទាក់ទងមក Child Support, Centrelink ឬ Medicare។

## 1. តើអ្នកមានសិទ្ធិចូលប្រើប្រាស់ឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនដែរឬទេ?

អ្នកអាចស្នើសុំឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនសម្រាប់អ្នក និងកូនៗរបស់អ្នកបាន។ នេះអាចរួមបញ្ចូលទាំងឯកសារនានាដូចតទៅនេះ៖

- ប័ណ្ណបើកបរ
- សំបុត្រកំណើត
- ព័ត៌មានលម្អិតទិដ្ឋាការ
- លិខិតឆ្លងដែន។

ប្រសិនបើអ្នកមិនមានចូលប្រើប្រាស់ឯកសារទាំងនេះទេ យើងនៅតែអាចជួយអ្នកបាន។ សូមទាក់ទងយើង ហើយយើងនឹងធ្វើការជាមួយអ្នកដើម្បីស្វែងរកជម្រើសផ្សេងទៀត។

## 2. តើអ្នកដឹងថាមានការបង់ប្រាក់អ្វីខ្លះដែលអ្នកអាចទទួលបាន?

ប្រើប្រាស់ Payment and Service Finder របស់យើងដើម្បីមើលថាតើមានការបង់ប្រាក់ និងសេវាកម្មអ្វីខ្លះដែលអ្នកប្រហែលជាអាចទទួលបាន។

អ្នកក៏អាចប្រើប្រាស់វាដើម្បីស្វែងរកសេវាកម្មនានាដែលនៅជិតអ្នកបានផងដែរ។ សូមជ្រើសរើសរដ្ឋ ឬដែនដី បន្ទាប់មកជ្រើសរើស គ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ។ សូមចូលទៅ **servicesaustralia.gov.au/paymentfinder** សម្រាប់ព័ត៌មានបន្ថែមទៀតជាភាសាអង់គ្លេស។

## 3. តើមានអ្នកណាផ្សេងទៀតទាក់ទងជាមួយយើងក្នុងនាមអ្នកដែរឬទេ?

យើងអាចជួយអ្នកបញ្ឈប់ការចាត់ចែងបាន ប្រសិនបើអ្នកណាម្នាក់ផ្សេងទៀត៖

- មានការអនុញ្ញាត្តិឱ្យទាក់ទងជាមួយ Centrelink, Medicare ឬ Child Support ក្នុងនាមខ្លួនអ្នក
- កំពុងទទួលបាន និងប្រើប្រាស់ការបង់ប្រាក់ Centrelink របស់អ្នក។

យើងនឹងប្រាប់ឱ្យអ្នកដឹង ប្រសិនបើយើងត្រូវការប្រាប់ភាគីផ្សេងទៀតអំពីការផ្លាស់ប្តូរ។

## 4. តើអ្នក ឬកូនៗរបស់អ្នកមាន My Health Record ដែរឬទេ?

My Health Record របស់អ្នក ឬកូនរបស់អ្នកអាចមានព័ត៌មានទំនាក់ទំនងដូចជាអាសយដ្ឋានរបស់អ្នកជាដើម។

ប្រសិនបើការធ្វើដូចនេះអាចធ្វើឱ្យគ្រួសាររបស់អ្នកមានហានិភ័យ សូមហៅទូរសព្ទទៅខ្សែទូរសព្ទជំនួយ My Health Record តាមលេខ **1800 723 471** និងជ្រើសរើស **ជម្រើសទី 1**។

## 5. តើអ្នកមានលក្ខខណ្ឌតម្រូវណាមួយដែលអ្នកត្រូវការដើម្បីបំពេញតាមដើម្បីទទួលបានការបង់ប្រាក់ Centrelink ដែរឬទេ?

អ្នកអាចត្រូវការបំពេញទៅតាមលក្ខខណ្ឌតម្រូវនានាក្នុងការចូលរួម ឬលក្ខខណ្ឌតម្រូវក្នុងកាតព្វកិច្ចទៅវិញទៅមក ដើម្បីទទួលបានការបង់ប្រាក់ Centrelink ។

សូមនិយាយមកកាន់យើង ឬអ្នកផ្តល់សេវារបស់អ្នក ប្រសិនបើអ្នកមិនអាចៈ

- ចូលរួមតាមការណាត់ជួបបាន
- បំពេញទៅតាមលក្ខខណ្ឌតម្រូវក្នុងការចូលរួម ឬលក្ខខណ្ឌតម្រូវក្នុងកាតព្វកិច្ចទៅវិញទៅមក។

## 6. តើអ្នកបានធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នកជាមួយយើងដែរឬទេ?

ជាផ្នែកនៃការរៀបចំផែនការសុវត្ថិភាពរបស់អ្នក សូមធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នកជាមួយ Child Support, Centrelink និង Medicare។ ការធ្វើបច្ចុប្បន្នភាពនេះអាចជាការធ្វើបច្ចុប្បន្នភាពលើអាសយដ្ឋានប្រៃសណីយ៍ ឬលេខទូរសព្ទថ្មី។

ការធ្វើនេះគឺដើម្បីធានាថាមានតែអ្នកប៉ុណ្ណោះ ដែលទទួលបានការបង់ប្រាក់ និងការធ្វើទំនាក់ទំនងពីយើង។

## 7. តើអ្នកត្រូវការផ្លាស់ប្តូរពាក្យសម្ងាត់ណាមួយរបស់អ្នកដែរឬទេ?

ប្រសិនបើមានអ្នកណាម្នាក់ផ្សេងទៀតមានការចូលប្រើប្រាស់គណនីនៅលើអ៊ីនធឺណិត ឬគណនី myGov របស់អ្នក នោះអ្នកផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នកនៅពេលណាក៏បាន។

ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសុវត្ថិភាពនៃកំណត់ត្រារបស់អ្នក សូមប្រាប់យើងឱ្យដឹង។ ឧទាហរណ៍ ប្រសិនបើអ្នកគិតថាមានអ្នកណាម្នាក់បានចូលប្រើប្រាស់គណនី myGov របស់អ្នក សូមទូរសព្ទទៅការិយាល័យជំនួយ myGov តាមលេខ **132 307** សម្រាប់ជំនួយជាភាសាអង់គ្លេស។

## 8. តើអ្នកត្រូវការផ្ទេរខ្លួនអ្នកផ្ទាល់ទៅកាត Medicare មួយទៀតដែរឬទេ?

អ្នកអាចផ្ទេរទៅកាត Medicare ថ្មី ប្រសិនបើវានៅតែមិនមានសុវត្ថិភាពនៅលើកាតមុន។

ដើម្បីធ្វើដូចនេះ សូមហៅទូរសព្ទទៅ Medicare តាមលេខ **132 011** ហើយប្រាប់យើងនូវអ្វីដែលអ្នកចង់ធ្វើជាភាសាអង់គ្លេស។ យើងនឹងណែនាំអ្នកទៅជំហានបន្ទាប់ទៀត។

## 9. តើអ្នកមានការចូលប្រើប្រាស់គណនីធនាគារដែលមានសុវត្ថិភាពក្នុងនាមឈ្មោះរបស់អ្នកផ្ទាល់ដែរឬទេ?

ជាផ្នែកនៃការរៀបចំផែនការសុវត្ថិភាពរបស់អ្នក អ្នកអាចមានការចូលប្រើប្រាស់ទៅកាន់គណនីធនាគារដោយសុវត្ថិភាព ក្នុងនាមជាឈ្មោះរបស់អ្នកតែប៉ុណ្ណោះ។

ប្រសិនបើអ្នកចង់ផ្ញើការបង់ប្រាក់របស់អ្នកទៅកាន់គណនីនោះ អ្នកនឹងត្រូវការផ្លាស់ប្តូរព័ត៌មានលម្អិតគណនីធនាគាររបស់អ្នក។ សូមចាំថា អ្នកនឹងត្រូវការធ្វើដូចនេះដាច់ដោយឡែកសម្រាប់ Centrelink, Medicare និង Child Support ។

## 10. តើអ្នកត្រូវការជំនួយដើម្បីយល់ដឹងអំពីព័ត៌មានរបស់យើងដែរឬទេ?

ប្រសិនបើអ្នកត្រូវការជំនួយដើម្បីយល់ដឹងអំពីការបង់ប្រាក់ និងសេវាកម្មនានារបស់យើង មានជម្រើសនានាអាចរកបាន។ ឧទាហរណ៍ យើងអាចជួយប្រសិនបើ៖

- អ្នកមានបញ្ហាក្នុងការស្តាប់ ឬការនិយាយ
- អ្នកត្រូវការនិយាយទៅកាន់អ្នកណាម្នាក់ជាភាសារបស់អ្នក
- អ្នក ឬអ្នកណាម្នាក់ដែលស្ថិតនៅក្រោមការថែទាំរបស់អ្នកមានពិការភាព ជំងឺ ឬរបួស។

ដើម្បីនិយាយមកកាន់យើងជាភាសារបស់អ្នក សូមហៅទូរសព្ទទៅ៖

- លេខ **131 202** អំពីការបង់ប្រាក់ និងសេវាកម្មរបស់ Centrelink
- សេវា Translating and Interpreting Service (TIS National) តាមលេខ **131 450** អំពី Medicare ឬការបង់ប្រាក់ និងសេវាកម្ម Child Support ។

សូមចូលទៅ **servicesaustralia.gov.au/accessibility** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។

អ្នកក៏អាចរកមើលព័ត៌មានជាភាសារបស់អ្នកនៅឯ **servicesaustralia.gov.au/yourlanguage**

## 11. តើអ្នកមានករណី child support បច្ចុប្បន្ន ឬត្រូវការដាក់ពាក្យសុំ child support សម្រាប់ Family Tax Benefitដែរឬទេ?

សូមហៅទូរសព្ទទៅ Child Support តាមលេខ **131 272** សម្រាប់ព័ត៌មានជាភាសាអង់គ្លេស ប្រសិនបើអ្នកមានការព្រួយបារម្ភអំពី៖

- ការស្វែងរក child support ពីអតីតដៃគូរបស់អ្នក
- យើងទាក់ទងទៅអតីតដៃគូរបស់អ្នក។

## 12. តើមានអាជីវកម្មផ្សេងទៀតដែលអ្នកត្រូវការដើម្បីនិយាយមកយើងដែរឬទេ?

អ្នកអាចនិយាយមកកាន់យើង ប្រសិនបើអ្នកមានសំណួរអំពី៖

- ការបង់ប្រាក់ ឬបំណុល Centrelink ការបង់ប្រាក់ ឬបំណុល
- ការបង់ប្រាក់ ឬដំណើរការ Medicare
- ការវាយតម្លៃ ឬបំណុល Child Support
- សុវត្ថិភាពនៃកំណត់ត្រា Child Support, Centrelink ឬ Medicare របស់អ្នក។

សូមចូលទៅ **servicesaustralia.gov.au/contact** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។

## 13. តើខ្ញុំអាចរកសេវាជំនួយ និងឧបករណ៍ផ្សេងទៀតនៅទីណា?

បុគ្គលិកសង្គមកិច្ចរបស់យើងផ្តល់ជូនការពិគ្រោះយោបល់ដោយឥតគិតថ្លៃ និងសម្ងាត់។ ពួកគេអាចបញ្ជូនអ្នកបន្តទៅសេវាកម្មផ្សេងទៀតដែលអាចជួយអ្នកបាន។ សូមហៅទូរសព្ទតាមខ្សែទូរសព្ទ Employment Services របស់យើងតាមលេខ **132 850** ហើយស្នើសុំបុគ្គលិកសង្គមកិច្ចម្នាក់។ សូមប្រាប់ឱ្យយើងដឹងប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់។ យើងនឹងចាត់ចែងរកអ្នកបកប្រែម្នាក់សម្រាប់អ្នកដោយឥតគិតថ្លៃ។

មានអង្គការផ្សេងទៀតដើម្បីជួយអ្នក។ អ្នកអាចរកមើលបញ្ជីជាភាសាអង់គ្លេសនៅឯ **servicesaustralia.gov.au/domesticviolence**

**1800RESPECT (1800 737 732)** មាន 24 ម៉ោង, ខ្សែទូរសព្ទជំនួយមាន 7 ថ្ងៃក្នុងមួយសប្តាហ៍ និង ‘ស្វែងរកមុខងារសេវាកម្មនានានៅក្នុងតំបន់របស់អ្នក’ ។

Ask Izzy គឺជាបញ្ជីឈ្មោះសម្រាប់ជួយអ្នកក្នុងការស្វែងរកសេវាកម្មនានានៅក្នុងតំបន់របស់អ្នក។ សូមចូលទៅ **askizzy.org.au**

# Family and domestic violence checklist

If you are concerned about your or your family's safety, we can help. Here are some things to keep in mind if you contact Child Support, Centrelink or Medicare.

## 1. Do you have access to personal identity documents?

We may ask for personal identity documents for you and your children. This could include documents like these:

- driver licence
- birth certificate
- visa details
- passport.

If you do not have access to them, we can still help you. Contact us and we will work with you to find other options.

## 2. Do you know what payments you can get?

Use our Payment and Service Finder to see what payments and services you may be able to get.

You can also use it to find services near you. Select your state or territory, then family and domestic violence. Go to **servicesaustralia.gov.au/paymentfinder** for more information in English.

## 3. Does someone else deal with us on your behalf?

We can help you end an arrangement if someone else:

- has permission to deal with Centrelink, Medicare or Child Support on your behalf
- is getting and using your Centrelink payment.

We will let you know if we need to tell the other party about the change.

## 4. Do you or your children have a My Health Record?

Your or your child's My Health Record can contain contact information such as your address.

If this could put your family at risk, call the My Health Record Help line on **1800 723 471** and select **option 1**.

## 5. Do you have any requirements you need to meet to get your Centrelink payment?

You may need to meet participation or mutual obligation requirements to get a Centrelink payment.

Talk to us, or your provider, if you cannot:

- attend an appointment
- meet your participation or mutual obligation requirements.

## 6. Have you updated your personal details with us?

As part of your safety planning, update your personal details with Child Support, Centrelink and Medicare. This could be a new postal address or phone number.

This is to make sure only you get payments and correspondence from us.

## 7. Do you need to change any of your passwords?

If someone else has access to your online or myGov accounts, you can change your passwords at any time.

If you are concerned about the security of your records, let us know. For example, if you think someone has accessed your myGov account, call the myGov help desk on **132 307** for help in English**.**

## 8. Do you need to transfer yourself to another Medicare card?

You can transfer to a new Medicare card if it is unsafe to remain on a previous card.

To do this, call Medicare on **132 011** and tell us what you want to do in English. We will direct you to the next step.

## 9. Do you have secure access to a bank account in your own name?

As part of your safety planning, you may have secure access to a bank account in your name only.

If you would like us to send your payments to that account, you will need to change your bank account details. Remember, you will need to do this separately for Centrelink, Medicare and Child Support.

## 10. Do you need help to understand our information?

If you need help to understand information about our payments and services, there are options available. For example, we can help if:

- you have a hearing or speech impairment
- you need to talk to someone in your language
- you or someone in your care have a disability, illness or injury.

To speak to us in your language, call:

- **131 202** about Centrelink payments and services
- the Translating and Interpreting Service (TIS National) on **131 450** about Medicare or Child Support payments and services.

Go to **servicesaustralia.gov.au/accessibility** for more information in English.

You can also find information in your language at **servicesaustralia.gov.au/yourlanguage**

## 11. Do you have a current child support case or need to apply for child support for your Family Tax Benefit?

Call Child Support on **131 272** for information in English if you are concerned about:

- seeking child support from your ex-partner
- us contacting your ex-partner.

## 12. Is there other business you need to talk to us about?

You can talk to us if you have questions about:

- Centrelink payments or debt
- Medicare payments or processes
- Child Support assessments or debt
- the security of your Child Support, Centrelink or Medicare records.

Go to **servicesaustralia.gov.au/contact** for more information in English.

## 13. Where can I find other support services and tools?

Our social workers provide free, confidential counselling. They can refer you to other services that might help. Call our Employment Services line on **132 850** and ask to speak to a social worker. Let us know if you need an interpreter. We will arrange one for free.

There are other organisations to help you. You can find a list in English at **servicesaustralia.gov.au/domesticviolence**

**1800RESPECT (1800 737 732)** has a 24 hour, 7 day a week helpline and ‘Find services in your area’ function.

Ask Izzy is a directory to help you find services in your area. Go to **askizzy.org.au**